**ព្រះរាជាណាចក្រ កម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង
# រវាង
# ក្រុមហ៊ុន ហ្ក្រេនឌីស ធីមប៊ើរ អិលធីឌី
# និង
# តំណាងប្រតិភូបុគ្គលិក
# ក្រុមហ៊ុន ហ្ក្រេនឌីស ធីមប៊ើរ អិលធីឌី
# ស្តីអំពីការព្យួរកិច្ចសន្យាការងារ

ឆ្នាំពីរពាន់ម្ភៃមួយ ខែ មិថុនា ថ្ងៃទី១០ វេលាម៉ោងដប់មួយព្រឹក នៅក្រុមហ៊ុនហ្ក្រេនឌីស ធីមប៊ើរ អិលធីឌី មានកិច្ចប្រជុំរវាងតំណាងក្រុមហ៊ុន និង ប្រតិភូបុគ្គលិក ប្រចាំក្រុមហ៊ុន ។

នៅក្នុងអង្គប្រជុំនេះ តំណាងក្រុមហ៊ុនបានធ្វើបច្ចុប្បន្នភាពអំពីស្ថានភាព របស់ក្រុមហ៊ុនដែលនឹងកំពុងតែជួបប្រទះ ជូនដល់បុគ្គលិកទាំងអស់ថាលំហូរសាច់ប្រាក់និងការព្យាករណ៍ការចំណាយនានានៅតែជាបញ្ហាប្រឈមសម្រាប់ក្រុមហ៊ុនក្នុងស្ថានភាពបច្ចុប្បន្ន ព្រោះវិបត្តិនៃការរីករាលដាលជាសាកលនៃជម្ងឺកូវីដ-១៩ និងថ្មីៗនេះព្រឹត្តិការណ៍សហគមន៍ ថ្ងៃ២០កុម្ភៈ បានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ការងារប្រតិបត្តិការចម្ការឈើ ផែនការប្រើប្រាស់ទុនវិនិយោគរបស់ក្រុមហ៊ុនយើងខ្ញុំ។ ដូច្នេះក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងាររបស់បុគ្គលិកចំនួន១នាក់ ក្នុងរយៈពេល ០២ខែ ដោយគិតចាប់ពីថ្ងៃ ០១ កក្កដា ឆ្នាំ ២០២១ រហូតដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០២១។ ក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុនបានព្រមព្រៀងផ្តល់ប្រាក់ឧបត្ថម្ភជូន កម្មករនិយោជិតចំនួន ៤០% នៃប្រាក់ខែគោល(គិតជាដុល្លាអាមេរិក)ក្នុង១ខែ សម្រាប់ និយោជិតម្នាក់ៗ ដោយបើកពីរដងក្នុងមួយខែ។ ករណីដែលក្រុមហ៊ុនមានការងារចាំបាច់ណាមួយដែលតម្រូវអោយបុគ្គលិកមកធ្វើការ ក្រុមហ៊ុននឹងបើកប្រាក់ឈ្នួលគិតតាមថ្ងៃដែលនិយោជិតបានមកធ្វើការ។

អង្គប្រជុំបានចប់វេលាម៉ោង ដប់មួយសាមសិបនាទីព្រឹក នាថ្ងៃខែឆ្នាំដដែលដោយភាគីទាំងសងខាងមានភាពស្និតស្នាល និងការយោគយល់គ្នាក្រោមស្មារតីទទួលខុសត្រូវ និង សហការគ្នាយ៉ាងរលូន ។

ដើម្បីបង្ហាញពីកិច្ចព្រមព្រៀងប្រជុំខាងលើ យើងខ្ញុំទាំងអស់គ្នាសូមផ្តិតមេដៃ ធ្វើជាសាក្សី ។

ស្នាមមេដៃតំណាងប្រតិភូបុគ្គលិក

លោកស្រី ហុង លីណា លោក មាស មករា

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ២០២១

**ហត្ថលេខាប្រធានប្រតិបត្តិ**

ហ្ក្រេនឌិស ធីមប៊ើរ អិលធីឌី
GRANDIS TIMBER
LTD.

**ហុង លីណា**